21-08-11

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ០៩ សរណន

# សារាចរណែនាំ
# ស្ដីពី
# ការគ្រប់គ្រងឡូត៍នេសាទដែលបានដកហូតចំនួន ៣៥ ឡូត៍ ជុំវិញបឹងទន្លេសាប នៅខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់

ក្នុងការអនុវត្តបទបញ្ជាលេខ ០១ បប ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១១ របស់រាជរដ្ឋាភិបាល ស្ដីពីការចាត់វិធានការលុបបំបាត់ភាពអនាធិបតេយ្យនៃការដាក់សម្រាស់ ឆ្នូស ព្រួល និងសំណង់កាត់ទទឹងទន្លេ ស្ទឹង ព្រែក អូរ នៅតាមបណ្ដាខេត្តពាក់ព័ន្ធនឹងបឹងទន្លេសាប និងការអនុវត្តសេចក្ដីសម្រេចលេខ ៣៩ សសរ ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១១ របស់រាជរដ្ឋាភិបាល ស្ដីពីការបង្កើតគណៈកម្មការអធិការកិច្ច លើការគ្រប់គ្រង និងអភិវឌ្ឍន៍ឡូត៍នេសាទជុំវិញបឹងទន្លេសាប រាជរដ្ឋាភិបាលបានសម្រេចដកហូតឡូត៍នេសាទចំនួន ៣៥ ឡូត៍ ជុំវិញបឹងទន្លេសាបនៅខេត្តចំនួន ៥ គឺខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់។

ដើម្បីរក្សាបាននូវធនធានមច្ឆជាតិ និងការប្រើប្រាស់ធនធានធម្មជាតិនៅបឹងទន្លេសាបប្រកបដោយនិរន្តរភាព ពិសេសគ្រប់គ្រងឡូត៍នេសាទទាំង ៣៥ ដែលបានដកហូតឱ្យបានល្អ ធានាទប់ស្កាត់បាននូវបទល្មើសនេសាទ និងការនេសាទបែបអនាធិបតេយ្យដែលអាចកើតមានក្នុងឡូត៍នេសាទទាំងនោះរហូតដល់មានការសម្រេចសារជាថ្មី រាជរដ្ឋាភិបាលធ្វើការណែនាំដូចតទៅៈ

១- អភិបាល នៃគណៈអភិបាលខេត្តទាំង ៥ (ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់) ក្នុងក្របខ័ណ្ឌភូមិសាស្ត្ររបស់ខ្លួនត្រូវដឹកនាំគណៈបញ្ជាការឯកភាពខេត្ត ~~តាមឡូត៍នេសាទដែលត្រូវបានដកហូត ដោយប្រើប្រាស់គ្រប់វិធានការចាំបាច់រួមទាំងវិធានការ~~ រដ្ឋបាល អប់រំ ច្បាប់ និងវិធានការផ្សេងៗទៀត ដើម្បីទប់ស្កាត់ការនេសាទអនាធិបតេយ្យ ពិសេសត្រូវទប់ស្កាត់ប្រជានេសាទចំណាកស្រុក សហគមន៍នេសាទ និងជនគ្រប់រូបមិនឱ្យប្រព្រឹត្តបទល្មើសនេសាទ។

២- អាជ្ញាធរទន្លេសាបក្រៅពីភារកិច្ចជំនាញ និងភារកិច្ចដែលបានប្រគល់ជូនតាមចំណុចទី ២ នៃលិខិតលេខ ១០០១ សជណ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១១ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ត្រូវធ្វើការសម្របសម្រួល ដឹកនាំ ត្រួតពិនិត្យ សំដៅបង្ការ ទប់ស្កាត់ កុំឱ្យមានការធ្វើនេសាទអនាធិបតេយ្យនៅក្នុងឡូត៍ដែលបានដកហូត។

៣- បណ្តាក្រសួងពាក់ព័ន្ធ ពិសេសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (រដ្ឋបាលជលផល) ក្រសួងបរិស្ថាន ក្រសួងធនធានទឹក និងឧត្តុនិយម ត្រូវបង្កលក្ខណៈលើកិច្ចការជំនាញរបស់ខ្លួនរួមទាំងផ្នែកសម្ភារៈ ថវិកា និងមន្ត្រីជំនាញ ពិសេសមន្ត្រីនៅថ្នាក់ក្រោមជាតិដើម្បីចូលរួមជាមួយគណៈបញ្ជាការឯកភាពខេត្ត ស្រុក ក្រុង ខណ្ឌ និង ឃុំ-សង្កាត់ ដែលពាក់ព័ន្ធនឹងឡូត៍នេសាទទាំង ៣៥ ដើម្បីគ្រប់គ្រងឡូត៍នេសាទទាំងនោះឱ្យបានល្អ។

៤- ក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ ត្រូវមានផែនការរៀបចំគ្រប់គ្រងប្រជាជនរស់នៅក្នុង និងជុំវិញបឹងទន្លេសាប ដើម្បីធានាសុវត្ថិភាព សន្តិសុខ រួមចំណែកក្នុងការការពារឡូត៍នេសាទដែលបានដកហូត។

៥- គណៈកម្មការអធិការកិច្ច លើការគ្រប់គ្រង និងអភិវឌ្ឍន៍ឡូត៍នេសាទជុំវិញបឹងទន្លេសាប ត្រូវបន្តដឹកនាំធ្វើអធិការកិច្ចលើយន្តការទាំងអស់ នៃការបង្ការ ទប់ស្កាត់ការនេសាទអនាធិបតេយ្យនៅតាមឡូត៍នេសាទទាំង ៣៥ ហើយទំនាក់ទំនងជាមួយស្ថាប័នតុលាការគ្រប់ថ្នាក់ ពិសេសសាលាដំបូងនៅខេត្តពាក់ព័ន្ធទាំង ៥ ដើម្បីរួមចំណែកអនុវត្តលិខិតលេខ ១០០១ សជណ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ឱ្យមានប្រសិទ្ធភាពខ្ពស់។

ទទួលបានសារាចរនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ គណៈកម្មការអធិការកិច្ច លើការគ្រប់គ្រង និងអភិវឌ្ឍន៍ឡូត៍នេសាទជុំវិញបឹងទន្លេសាប ត្រូវអនុវត្តសារាចរនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
~~-អគ្គលេខាធិការរាជរដ្ឋាភិបាល~~
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-សាលាខេត្តបាត់ដំបង សៀមរាប កំពង់ធំ កំពង់ឆ្នាំង ពោធិ៍សាត់ "ដើម្បីអនុវត្ត"
-គ្រប់សាលារាជធានី ខេត្ត "ដើម្បីសហការអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ